**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌

លេខ ១១៧ សរ.រវ-៩៧

# **សេចក្តីបង្គាប់**

**ស្តីពីការអនុវត្តសាលក្រម សាលដីកាស្ថាពរ**

**និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ ។**

## **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**សូមជ្រាប**

សូមជ្រាបអស់លោកប្រធានតុលាការនិងព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងថា ដោយសព្វថ្ងៃយើងមិនទាន់មានច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យអង្គការណាមួយដើម្បីយកសាលក្រមឬសាលដីកាស្ថាពរឬដីកាផ្សេងៗ ទៀតរបស់តុលាការគ្រប់ជាន់ថ្នាក់ ទៅអនុវត្តតាមច្បាប់ស្តីពីវិធីអនុវត្តសាលប្រនៅឡើយ ហើយកន្លងមកការអនុវត្តសេចក្តីសម្រេចទាំងនេះ តែងតែជួបប្រទះនឹងភាពរឹងរូស រហូតដល់មានការទប់ទល់ប្រឆាំងដោយប្រដាប់អាវុធធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈក្នុងសង្គមបង្កើតជាបទល្មើសមជ្ឈឹមឬឧក្រិដ្ឋថែមទៀត ។

ដោយព្រះរាជអាជ្ញាជាមន្ត្រីនគរបាលយុត្តិធម៌ មានតួនាទីជាអ្នកដឹកនាំកិច្ចប្រតិបត្តិការទាំងឡាយនៃមន្ត្រីនគរបាលយុត្តិធម៌និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌ ស្វែងរកជនល្មើស កេណ្ឌកំលាំងសាធារណៈរុករកនិងប្រមូលភស្តុតាងនៃអំពើល្មើសមានសិទ្ធិធ្វើការឆែកឆេរឹបអូសវត្ថុតាង និងឃាត់ខ្លួនជនល្មើសក្នុងករណីមានបទមជ្ឈឹមឬឧក្រិដ្ឋជាក់ស្តែងកើតឡើង ដើម្បីរក្សារបៀបរៀបរយសាធារណៈក្នុងសង្គម ។

ដោយយោលតាមសភាពការណ៍ខាងលើនេះ ក្រសួងយុត្តិធម៌សម្រេចប្រគល់សមត្ថកិច្ចជូនព្រះរាជអាជ្ញាដឹកនាំអនុវត្តដោយផ្ទាល់ជាបណ្តោះអាសន្ននូវសេចក្តីសម្រេចទាំងអស់ និងដីកាផ្សេងៗទៀតរបស់តុលាការគ្រប់ជាន់ថ្នាក់ក្នុងរង្វង់សមត្ថកិច្ចដែនដីរបស់ខ្លួន ទំរាំមានច្បាប់កំណត់អំពីបញ្ហានេះ ប្រសិនបើមានការស្នើសុំត្រឹមត្រូវតាមច្បាប់ គឺអ្នកឈ្នះក្តីឬពីអ្នកទទួលសិទ្ធិពីអ្នកឈ្នះក្តី ។

ប្រធានតុលាការ ឬចៅក្រមដែលប្រធានតុលាការចាត់តាំងឱ្យទទួលភារកិច្ចក្នុងរឿងក្តីណាមួយមានតួនាទីជាអ្នកត្រួតពិនិត្យរួចវិនិច្ឆ័យសេចក្តីទៅពេលដែលមានពាក្យបណ្តឹងតវ៉ា អំពីចំណុចខាតនៃការអនុវត្តន៍សាលក្រម ឬសាលដីកា ជនដែលត្រូវរឹបអូសពីម្ចាស់បំណុលនៃជនដែលត្រូវរឹបអូស ឬពីតតីយជនណាមួយដែលមានផលប្រយោជន៍ក្នុងរឿងនោះ ។

ក្រសួងយុត្តិធម៌ សូមលោកព្រះរាជអាជ្ញា និងលោកប្រធានតុលាការគ្រប់ខេត្ត ក្រុង អនុវត្តតាមបញ្ហានេះចប់ពីថ្ងៃនេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

**អ្នកទទួល**

-ប្រធានតុលាការខេត្ត ក្រុង
-ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង (ដើម្បីអនុវត្ត)
-ក្រសួងមហាផ្ទៃ
-ប្រធានតុលាការកំពូល
-អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
-អភិបាលខេត្ត ក្រុង
-ប្រធានសាលាឧទ្ធរណ៍
-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
-នាយកដ្ឋានព្រហ្មទណ្ឌ នឹងរដ្ឋប្បវេណី
-នាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាល ក្រសួងយុត្តិធម៌
-មន្ទីរក្រសួងយុត្តិធម៌
-តុលាការយោធា
-ព្រះរាជអាជ្ញាអមតុលាការយោធា
-គណៈមេធាវី (ដើម្បីជ្រាប)
-មជ្ឈមណ្ឌលតម្កល់ឯកសារ ដើម្បីតម្កល់